00778574

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL/DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 14 / 02 / 2012
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លេខ/No: D5/2/4/3

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ០២)

ចំពោះមុខៈ
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទៈ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២

---

សាធារណៈ (សំណៅកោសលុប)

**សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងជំទាស់នឹងដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill**

---

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**មេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

សំ សុគង់
Lyma Thuy NGUYEN

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់លោក Robert Hamill (D11/2/3) (សំណុំរឿងលេខ 00៣ និង 00៤) ដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (“សហមេធាវី”) បានដាក់នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២0១១ (“បណ្តឹងឧទ្ធរណ៍”)[១]។

## I. **ប្រវត្តិនីតិវិធី និង សារណា**

១. នៅថ្ងៃទី ២0 ខែ វិច្ឆិកា ឆ្នាំ ២00៨ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣[២] ជូនទៅសហចៅក្រមស៊ើបអង្កេត ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរលើសំណុំរឿង 00៤។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ នេះត្រូវបានដាក់ជាឯកសារសម្ងាត់ ហេតុដូច្នេះមិនមានភាគីណាមួយ រួមបញ្ចូលទាំងសាធារណៈជន ជនរងគ្រោះ និង អ្នកដែលអាចជាភាគីដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិចូលមើលឯកសារនេះទេ។[៣]

២. នៅថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២0១១ លោក Robert Hamill (“ម្ចាស់បណ្តឹងឧទ្ធរណ៍”) បានដាក់ពាក្យសុំទៅអង្គភាពគាំពារជនរងគ្រោះនៃ អ.វ.ត.ក (“ពាក្យសុំ” និង “អង្គភាពគាំពារជនរងគ្រោះ”) ដោយស្នើសុំឱ្យទទួលស្គាល់ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង 00៣ និង 00៤ នៅចំពោះមុខ អ.វ.ត.ក។ នៅក្នុងពាក្យសុំនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍អះអាងថា ខ្លួនបានទទួលរងព្យសនកម្ម ដោយសារផលវិបាកដោយផ្ទាល់នៃបទល្មើសទាំងឡាយ ដែលបានប្រព្រឹត្តទៅលើបងប្រុសរបស់ខ្លួន ឈ្មោះ Kerry Hamill។ បងប្រុសរបស់ខ្លួនរូបនេះ ត្រូវបានកងទ័ពជើងទឹក

---

[១] បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill (D11/2/3) (សំណុំរឿងលេខ 00២ និង 00៣) ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២0១១ ឯកសារលេខ D5/2/4/2 (“បណ្តឹងឧទ្ធរណ៍”)។

[២] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២0 ខែ វិច្ឆិកា ឆ្នាំ ២00៨ ឯកសារលេខ D1។ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី នៃការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរទី៣ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២00៩ ឯកសារលេខ D1/1។

[៣] វាត្រូវកត់សម្គាល់ថា នៅថ្ងៃទី ៨ ខែ កញ្ញា ២00៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានបញ្ជាក់ជាសាធារណៈ តាមរយៈសេចក្តីប្រកាសពត៌មាន ពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ (សេចក្តីប្រកាសពត៌មាន៖ សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី នៅថ្ងៃទី 0៨ ខែ កញ្ញា ២00៩)។

នៃរបបកម្ពុជាប្រជាធិបតេយ្យចាប់ខ្លួននៅក្នុងខែ សីហា ឆ្នាំ ១៩៧៨ និងក្រោយមក ត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ ដើម្បីឃុំខ្លួន សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ចោល[៤]។ ពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវបានអង្គភាពគាំពារជនរងគ្រោះបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១[៥]។

៣. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ជាថ្ងៃដដែល ដែលសហចៅក្រមស៊ើបអង្កេតបានសេចក្តីសន្និដ្ឋានបិទកិច្ចស៊ើបសួរ នៅក្នុងសំណុំរឿង ០០៣ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចចំនួនពីរ ពោលគឺ "ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill"[៦] (ដីកាសម្រេចក្នុងសំណុំរឿង ០០៣) និង "ដីកាសម្រេច លើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill"[៧] ("ដីកាសម្រេចក្នុងសំណុំរឿង ០០៤)"។ ដីកាសម្រេចទាំងពីរនេះបានប្រកាសមិនទទួលយកពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយមានសំអាងហេតុផ្សេងៗគ្នា។ ដីកាសម្រេចក្នុងសំណុំរឿង ០០៤ សម្រេចបដិសេធពាក្យសុំនេះ ដោយផ្អែកលើមូលដ្ឋានថា "គ្មានអង្គហេតុណាមួយ ក្នុងចំណោមអង្គហេតុជាក់ស្តែងនានា" ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានចោទប្រកាន់ថាបានកើតឡើង ចំពោះបងប្រុសរបស់គាត់នោះ "ពាក់ព័ន្ធទៅនឹងអង្គហេតុសត្យានុម័តដែល

---

[៤] ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ចុះហត្ថលេខានៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ និងបានដាក់ជូនអង្គភាពគាំពារជនរងគ្រោះ នៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D5/2 (ពាក្យសុំ)។

[៥] ពាក្យសុំ ដែលមានត្រា ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១ ដោយមន្ត្រីគ្រប់គ្រងសំណុំរឿង ប៉ុន្តែទើបតែបានដាក់បញ្ចូលនៅក្នុងសំណុំរឿង នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ តែប៉ុណ្ណោះ ដូចបានបញ្ជាក់នៅលើទម្រង់បែបបទអំពីការណែនាំស្តីពីការដាក់ឯកសារ។

[៦] ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D11/2/3 (ដីកាសម្រេចក្នុងសំណុំរឿង ០០៣) ពោលគឺជាដីកាដំបូង ដែលត្រូវបានដាក់ និងជូនដំណឹងដល់ម្ចាស់បណ្តឹងឧទ្ធរណ៍។ ដីកាដែលត្រូវបានកែប្រែ ត្រូវបានដាក់នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ដោយគ្មានការជូនដំណឹងដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ ឬក៏អង្គបុរេជំនុំជម្រះ៖ ចំពោះការពិភាក្សាលើបញ្ហានេះ សូមមើលសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ចុះថ្ងៃទី ២៤ ខែ តុលា ឯកសារលេខ D11/2/4/4។

[៧] ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D5/2/3 ("ដីកាសម្រេចក្នុងសំណុំរឿង ០០៤)"។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00778577



មាននៅក្នុងដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរទី៣ [sic.] ឬក៏អង្គហេតុ ទាំងនោះពាក់ព័ន្ធទៅនឹងកាលៈទេសៈជុំវិញអង្គហេតុសត្យានុម័តនោះទេ ឬថាអង្គហេតុទាំងនោះ នឹងមិនជួយដល់ការសម្រេចទៅលើធាតុផ្សំយុត្តាធិការ និងទម្រង់នៃការទទួលខុសត្រូវរបស់អ្នក ដែលទំនងជាជនសង្ស័យនោះទេ”[៨]។ សហចៅក្រមស៊ើបអង្កេតក៏បានយល់ឃើញផងដែរថា ការចោទប្រកាន់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ថា ព្យសនកម្មរបស់ខ្លួនគឺជា “ផលវិបាកផ្ទាល់នៃអំពើដែលបានចោទប្រកាន់ថាបានប្រព្រឹត្តដោយ [redacted]” គឺ “គ្រាន់តែជាការប៉ាន់ស្មានសុទ្ធសាធ” ដោយហេតុថា ឈ្មោះរបស់ជនសង្ស័យត្រូវបានរក្សាជាការសម្ងាត់[៩] ហើយសហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ព្យសនកម្មរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ “មិនពាក់ព័ន្ធទៅនឹងអង្គហេតុណាមួយនៃអង្គហេតុ ដែលស្ថិតនៅក្នុងការស៊ើបអង្កេតនោះទេ”[១០]។

៤. នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១ សហមេធាវីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ជូនសហចៅក្រមស៊ើបអង្កេត ដោយបានចង្អុលបញ្ជាក់ថា ខ្លួន និងម្ចាស់បណ្តឹងឧទ្ធរណ៍ ពុំបានទទួលដីកាសម្រេចក្នុងសំណុំរឿង ០០៤ ឡើយ។ សហមេធាវីបានចង្អុលបង្ហាញថា ដីកាសម្រេចក្នុងសំណុំរឿង ០០៣ បានលើកឡើងថា ពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវបានបដិសេធ “នៅក្នុងសំណុំរឿង ០០៤”។ ក៏ប៉ុន្តែ ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ខ្លួនថា ដីកាសម្រេចដោយឡែកមួយទៀត ត្រូវបានចេញដាច់ដោយឡែកសម្រាប់សំណុំរឿង ០០៤[១១]។ នៅក្នុងសៀវភៅចុះបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានលើកឡើងថា សហមេធាវីពុំទាន់ត្រូវបានសហចៅក្រមស៊ើបអង្កេតទទួលស្គាល់នៅឡើយទេ ហើយដីកាសម្រេចក្នុងសំណុំរឿង ០០៤ ត្រូវបានប្រគល់ជូនទៅម្ចាស់បណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១ រួចហើយ[១២]។

---

[៨] ដីកាសម្រេចក្នុងសំណុំរឿង ០០៤ កថាខណ្ឌ ១០។

[៩] ដីកាសម្រេចក្នុងសំណុំរឿង ០០៤ កថាខណ្ឌ ១១។

[១០] ដីកាសម្រេចក្នុងសំណុំរឿង ០០៤ កថាខណ្ឌ ១២។

[១១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣ និង ៤។

[១២] សៀវភៅចុះបណ្តឹងឧទ្ធរណ៍ ឯកសារលេខ D5/2/4 ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១។

E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00778578



៥. នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១ សហមេធាវីបានដាក់ "សំណើសុំពន្យារកាលបរិច្ឆេទកំណត់សម្រាប់ការដាក់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើពីភាពអាចទទួលយកបាន ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ក្នុងពេលរង់ចាំការអនុញ្ញាតពិនិត្យសំណុំរឿង ០០៣ និង ០០៤" ("សំណើសុំពិនិត្យសំណុំរឿង") ដោយសូមស្នើឱ្យអង្គបុរេជំនុំជម្រះអនុវត្តឆន្ទានុសិទ្ធិ ដើម្បីពន្យារកាលបរិច្ឆេទកំណត់ក្នុងការដាក់បណ្ដឹងឧទ្ធរណ៍ ក្នុងអំឡុងពេលមួយសមស្រប បន្ទាប់ពីអ្នកតំណាងផ្លូវច្បាប់របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍បានទទួលសិទ្ធិមើលសំណុំរឿង ឬ ដើម្បីអនុញ្ញាតឱ្យសហមេធាវីរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ អាចដាក់បន្ថែមនូវទឡ្ហីករណ៍លើអង្គច្បាប់ និងលើអង្គហេតុ ក្នុងរយៈពេលមួយសមស្រប ក្រោយពីបានទទួលសិទ្ធិក្នុងការពិនិត្យមើលសំណុំរឿងរួចហើយ[១៣]។ សហមេធាវីបានសន្និដ្ឋានថា ទោះបីជាសំណើរបស់ខ្លួនបានធ្វើឡើងជូនសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី១ ខែ ឧសភា ឆ្នាំ ២០១១ ក៏ដោយ ក៏ខ្លួនពុំទទួលបានការអនុញ្ញាតពិនិត្យសំណុំរឿងនៅក្នុងសំណុំរឿង ០០៤ នៅឡើយ[១៤]។ សហមេធាវីបានចោទប្រកាន់ទៀតថា បើទោះជាក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានលើកឡើងនៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ ថា ដីកាសម្រេចចំនួនពីរត្រូវបានចេញរួចហើយក៏ដោយ ក៏ម្ចាស់បណ្ដឹងឧទ្ធរណ៍ និងសហមេធាវីរបស់ខ្លួនពុំបានទទួលដីកាសម្រេចក្នុងសំណុំរឿង០០៤ នេះដែរ[១៥]។

៦. នៅក្នុងថ្ងៃនោះផងដែរ សហមេធាវីបានដាក់បណ្ដឹងឧទ្ធរណ៍របស់ខ្លួន នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយអះអាងថា គិតមកត្រឹមថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១១ ខ្លួន រួមទាំងម្ចាស់បណ្ដឹងឧទ្ធរណ៍ពុំទាន់បានទទួលដីកាសម្រេចក្នុងសំណុំរឿង ០០៤ នៅឡើយទេ ទោះបីជាខ្លួនបានព្យាយាមស្នើសុំដីកាសម្រេចនេះម្ដងហើយម្ដងទៀតក៏ដោយ[១៦]។ អាស្រ័យហេតុនេះ សហមេធាវីបានដាក់បណ្ដឹងឧទ្ធរណ៍តែមួយ ដើម្បីប្ដឹងតវ៉ាលើដីកាសម្រេចក្នុងសំណុំរឿង ០០៣ ដែល"បដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ របស់ [ម្ចាស់បណ្ដឹង

---

[១៣] សំណើសុំពន្យារកាលបរិច្ឆេទកំណត់សម្រាប់ការដាក់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាស្ដីពីភាពអាចទទួលយកបានចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ក្នុងពេលកំពុងរង់ចាំការអនុញ្ញាតឱ្យពិនិត្យមើលសំណុំរឿង ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ ដាក់នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D5/2/4/1 ("សំណើសុំ") កថាខណ្ឌ ៥។

[១៤] សំណើសុំចូលពិនិត្យសំណុំរឿង កថាខណ្ឌ ៤។

[១៥] សំណើសុំចូលពិនិត្យសំណុំរឿង កថាខណ្ឌ ១-២ និងលេខយោងជើងទំព័រ ១។

[១៦] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤ និង ៦។

00778579



ខទ្ធរណ៍]"[១៧]។ អង្គបុរេជំនុំជម្រះបានដោះស្រាយបណ្ដឹងឧទ្ធរណ៍ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០៣ នៅក្នុងសេចក្ដីសម្រេចដោយឡែករួចហើយ[១៨]។

៧. នៅក្នុងបណ្ដឹងឧទ្ធរណ៍បច្ចុប្បន្ន ដែលបានដាក់ ដោយអនុលោមតាមវិធាន ៧៧ *ស្ទួន* នៃវិធានផ្ទៃក្នុង សហមេធាវីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ៖ i) ប្រកាសថា បណ្ដឹងឧទ្ធរណ៍នេះអាចទទួលយកបាន ii) ច្រានចោលនូវសេចក្ដីសម្រេច នៅក្នុងដីការបស់សហចៅក្រមស៊ើបអង្កេតដែលសម្រេចបដិសេធមិនទទួលយកម្ចាស់បណ្ដឹងឧទ្ធរណ៍ជាដើមបណ្ដឹងរដ្ឋប្បវេណី iii) សម្រេចលើឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ម្ចាស់បណ្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤[១៩]។ ចំពោះទឡ្ហីករណ៍ទាំងឡាយដែលបានដាក់ជូននៅក្នុងសំណុំរឿង ០០៤ ឬក៏ទឡ្ហីករណ៍ ដែលបានដាក់ក្នុងគោលបំណងគាំទ្រលើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ បណ្ដឹងឧទ្ធរណ៍នេះបានលើកឡើងនូវមូលដ្ឋានចំនួន ៥ ដូចតទៅ ដែលមូលដ្ឋានទាំងនេះ ជាសំខាន់នោះ គឺបានផ្អែកលើដីកាសម្រេចដែលត្រូវបានចេញនៅក្នុងសំណុំរឿង ០០៣[២០] ពោលគឺ i) សហចៅក្រមស៊ើបអង្កេតខកខានពុំបាន "ធានានូវសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព" ដែលជាការរំលោភបំពានលើវិធាន ២១(គ) នៃវិធានផ្ទៃក្នុង នៅពេលសម្រេចបដិសេធពាក្យសុំរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋានថា ម្ចាស់បណ្ដឹងឧទ្ធរណ៍គឺជា "ជនរងគ្រោះដោយប្រយោល"[២១] ii) សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានលើវិធាន ២៣ *ស្ទួន* (១)(ខ) នៃវិធានផ្ទៃក្នុង និងមាត្រា ៣.២ (គ) នៃសេចក្ដីណែនាំអនុវត្តស្ដីពីការចូលរួមរបស់ជនរងគ្រោះ ដោយយល់ឃើញថា ម្ចាស់បណ្ដឹងឧទ្ធរណ៍មិនបានបង្ហាញថា ខ្លួនបានទទួលរងនូវការខូចខាត

---

[១៧] ដីកាសម្រេចក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ២ នៃការសម្រេចសេចក្ដី។ បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤។

[១៨] សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ D11/2/4/4។

[១៩] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៩ ដល់ ១១ និង ១០៩។

[២០] អង្គបុរេជំនុំជម្រះសង្កេតឃើញថា បណ្ដឹងឧទ្ធរណ៍នេះលើកឡើងនូវមូលដ្ឋានបន្ថែមមួយទៀត (មូលដ្ឋានទី ៥ នៃបណ្ដឹងឧទ្ធរណ៍ ដោយយោងទៅលើបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ៨៤ ដល់ ១០១) ដោយចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតខកខានមិនបាន "ស៊ើបអង្កេតលើសំណុំរឿង ០០៣ ឲ្យបានត្រឹមត្រូវ និងដោយឯករាជ្យ"។ ក៏ប៉ុន្តែ មូលដ្ឋានមួយនេះលើកឡើងនូវទឡ្ហីករណ៍ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ តែប៉ុណ្ណោះ ហើយទោះក្នុងវិធីណាក៏ដោយ មូលដ្ឋាននេះពុំពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ឡើយ។

[២១] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ២២ ដល់ កថាខណ្ឌទី ៤៣។



E.C.C.C. • C.E.T.C. TRIAL CHAMBER CHAMBRE PRELIMINAIRE

ខាងផ្លូវចិត្ត ដូចបានចោទប្រកាន់ ដែលការខូចខាតនេះគឺជាផលវិបាកដោយផ្ទាល់នៃមរណភាពរបស់បងប្រុសខ្លួន[២២] iii) សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានវិធាន ៥៦ និងវិធាន ២១ នៃវិធានផ្ទៃក្នុង រួមទាំងគោលការណ៍មូលដ្ឋាននៃសិទ្ធិជនរងគ្រោះ[២៣] និងគោលការណ៍ជាសារវ័ន្តនៃភាពយុត្តិធម៌ផ្នែកនីតិវិធី នៅពេលខ្លួនខកខានមិនបានផ្តល់ព័ត៌មានជាសាធារណៈអំពីវិសាលភាពនៃកិច្ចស៊ើបសួរសម្រាប់សំណុំរឿង ០០៤[២៤] iv) សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានវិធាន ២១ នៃវិធានផ្ទៃក្នុង "ពាក់ព័ន្ធនឹងគោលការណ៍មូលដ្ឋាន [sic] នៃភាពយុត្តិធម៌ផ្នែកនីតិវិធី ក្នុងការផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេច" នៅពេលខ្លួនខកខានពុំបានផ្តល់សំអាងហេតុសមរម្យនៅក្នុងសេចក្តីសម្រេច បដិសេធពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤[២៥] និង v) នៅពេលបដិសេធពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេត "បានរារាំងដំណើរការស្វែងរកយុត្តិធម៌របស់ អ.វ.ត.ក ដែលជនរងគ្រោះ និងសហគមន៍អន្តរជាតិ បានផ្តល់សេចក្តីសង្ឃឹម ហើយនៅពេលធ្វើដូច្នេះ សហចៅក្រមស៊ើបអង្កេតបានបង្កើតនូវសារមួយថា និទណ្ឌភាពគឺជាបញ្ហាធម្មតា ដោយបានរំលោភលើគោលបំណងចម្បងរបស់ អ.វ.ត.ក ដូចមានចែងនៅក្នុងច្បាប់ [អ.វ.ត.ក]"។[២៦]

៨. ពុំមានចម្លើយតបណាមួយត្រូវបានដាក់ចំពោះបណ្តឹងឧទ្ធរណ៍នេះទេ។

## II. **ការសម្តែងមតិយោបល់ និងសេចក្តីសន្និដ្ឋាន**

៩. ទោះបីមានការខិតខំប្រឹងប្រែងយ៉ាងណាក្តី អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ដែលចាំបាច់ដើម្បីអាចចេញសេចក្តីសម្រេចមួយលើបញ្ហានានានៅក្នុងបណ្តឹងឧទ្ធរណ៍ និងលើសំណើសុំពិនិត្យសំណុំរឿង ឬក៏លើវិធីសាស្ត្រសម្រាប់ដោះស្រាយបណ្តឹង

---

[២២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៤៤ ដល់ កថាខណ្ឌទី ៦០។

[២៣] សម័យប្រជុំពេញអង្គរបស់អង្គការសហប្រជាជាតិ សេចក្តីប្រកាសស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ និងការរំលោភអំណាច សេចក្តីសម្រេចលេខ ៤០/៣៤. ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥។

[២៤] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៦១ ដល់ កថាខណ្ឌទី ៧២។

[២៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៧៣ ដល់ កថាខណ្ឌទី ៨៣។

[២៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ១០២ ដល់ កថាខណ្ឌទី ១០៨។

00778581



ឧទ្ធរណ៍ និងសំណើនេះឡើយ។ ដោយហេតុថា វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងចែងថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះត្រូវមានសំអាងហេតុ ហេតុដូច្នេះទើបមតិយោបល់របស់ចៅក្រមអង្គជំនុំជម្រះ ត្រូវបានដាក់ភ្ជាប់នឹងសេចក្ដីពិចារណាទាំងនេះ។

១០. ដោយសារថា អង្គបុរេជំនុំជម្រះមិនបានចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ និងសំណើសុំនេះ វិធាន ៧៧(១៣)(ក) កំណត់ថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានតម្កល់ទុកជាបានការ។ សំអាងហេតុដូចគ្នា ត្រូវយកមកអនុវត្តលើសំណើសុំពិនិត្យសំណុំរឿង ពោលគឺសំណើសុំនេះពុំអាចទទួលយកបាន ដោយហេតុថា គ្មានសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមចំនួន ៤ រូបយ៉ាងតិច។

## III. **ការសម្រេចសេចក្ដី**

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសូម៖**

**ប្រកាសជាឯកច្ឆន្ទថា** អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ក្នុងការចេញសេចក្ដីសម្រេចលើសំណើសុំពិនិត្យសំណុំរឿងនេះបានឡើយ។

**ប្រកាសជាឯកច្ឆន្ទថា** អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ក្នុងការចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍នេះបានឡើយ។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ភាគីមិនមានលទ្ធភាពប្ដឹងតវ៉ាទេ។

**ភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Rowan DOWNING** **ន៍យ ថុល** **Katinka LAHUIS** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គឹម សាន ចៅក្រម ន៍យ ថុល និង ចៅក្រម ហួត វុទ្ធី សូមដាក់ភ្ជាប់មតិយោបល់របស់ខ្លួន។

ចៅក្រម Downing និង ចៅក្រម Lahuis សូមដាក់ភ្ជាប់មតិយោបល់របស់ខ្លួន។

# យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ផុល និងចៅក្រម ហួត វុទ្ធី

១. ក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill (D11/2/3) ("បណ្តឹងឧទ្ធរណ៍")[១] លោកបានបញ្ជាក់ថា លោកបានផ្តល់សក្ខីកម្ម នៅក្នុងសំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ (ហៅ ឌុច) ដែលជាប្រធានមន្ទីរស.២១ អំពីជោគវាសនារបស់បងប្រុសគាត់ឈ្មោះ Kerry Hamill ដែលគាត់ត្រូវបានឃុំឃាំង សួរចម្លើយធ្វើទារុណកម្ម និងសម្លាប់នៅ ស.២១[២]។ នៅក្នុងទម្រង់បែបបទស្តីពីពត៌មានជនរងគ្រោះរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍(11-VSS-00002) លោកបានរៀបរាប់អង្គហេតុថា នៅថ្ងៃទី ១៣ ខែសីហា ឆ្នាំ១៩៧៨ បងប្រុសម្ចាស់បណ្តឹងឧទ្ធរណ៍ ឈ្មោះ Kerry George Hamill ជាមេក្រុម និងជាសហាកម្មសិទ្ធិករទូកក្តោងប្រវែង ២៨ ហ្វ៊ីត ឈ្មោះ Foxy Lady ជាមួយសហាកម្មសិទ្ធិករម្នាក់ទៀតជាជនជាតិកាណាដា ឈ្មោះ Stuart Glass និងអ្នកដំណើរម្នាក់ជាជាតិអង់គ្លេសឈ្មោះ John Dewhirst បានឈប់សុំចតនៅលើឆកមួយនៃកោះតាង ដែលមានចម្ងាយ ៥០ គីឡូម៉ែត្រ ពីឆ្នេរភាគនិរតីក្រុងព្រះសីហនុ។ នៅល្ងាចនោះ មានការបាញ់សំដៅទៅលើទូកក្តោង Foxy Lady និងនាវិកទាំងអស់។ Stuart Glass ដែលនៅលើដំបូល ត្រូវបាន គេបាញ់ត្រូវ។ Kerry នៅលើដំបូលដែរ ក៏ជួយលើក Stuart ដាក់លើទូកសង្គ្រោះ។ John Dewhirst ដែលនៅ ក្រោមដំបូលនាពេលបាញ់នោះ ក៏ឡើងមកលើ រួចគេចខ្លួនជាមួយ Kerry ដោយលោតចូលទៅក្នុងទឹក[៣]។ បន្ទាប់មក ទូកខ្មែរក្រហមដែលមានអាវុធ ក៏ចូលទៅចាប់បុរសទាំងពីរនាក់នោះ។ Stuart បានស្លាប់បាត់បង់ជីវិត រួចត្រូវបានបោះចូលក្នុងសមុទ្រ។ បុរសទាំងពីរនាក់នោះត្រូវបានគេដាក់ច្រវាក់ជើង និងចងមុខ ហើយបន្ទាប់មកត្រូវបានគេនាំយកទៅឃុំឃាំងក្នុងរោងកុនមួយនៅក្រុងព្រះសីហនុ រយៈពេលមួយ ឬពីរថ្ងៃ មុននឹងបញ្ជូនទៅមន្ទីរសន្តិសុខ ស.២១ នៅភ្នំពេញ[៤]។ នៅ ស.២១ បុរសទាំងពីរនាក់ត្រូវបានគេសួរចម្លើយ និងធ្វើទារុណកម្ម រួមមានការឆក់ខ្សែរភ្លើងផង។ នៅទីបំផុត អ្នកទាំងពីរត្រូវបានគេបង្ខំឱ្យចុះហត្ថលេខាលើចម្លើយសារភាព ដោយអះអាងថា ពួកគេជាភ្នាក់ងារសេអ៊ីអា។ ចម្លើយសារភាពទាំងនេះមិនពិតទាល់តែសោះ[៥]។ នៅក្នុងចម្លើយសារភាពក្លែងក្លាយរបស់ Kerry បានប្រឌិតរឿងរ៉ាវអំពី "ការហ្វឹកហ្វឺន

---

[១] បណ្តឹងឧទ្ធរណ៍ របស់លោក Robert Hamill D5/2/4/2។

[២] កថាខណ្ឌទី ២៥ នៃបណ្តឹងឧទ្ធរណ៍ D5/2/4/2។

[៣] កថាខណ្ឌទី ២៦ នៃបណ្តឹងឧទ្ធរណ៍ D5/2/4/2។

[៤] កថាខណ្ឌទី ២៧ ៖ នៃបណ្តឹងឧទ្ធរណ៍ D5/2/4/2។

[៥] កថាខណ្ឌទី ២៨ នៃបណ្តឹងឧទ្ធរណ៍ D5/2/4/2។

បស់សេអ៊ីអា" ដោយបញ្ចូលទៅក្នុង ហេតុការណ៍ពិតក្នុងជីវិតរបស់គាត់។ Kerry បានប្រើលេខទូរស័ព្ទនៅផ្ទះគ្រួសារ Hamill នាពេលនោះ (៨៧០៨) ជាលេខប្រតិបត្តិការរបស់សេអ៊ីអា គាត់បានរៀបរាប់ថាវរៈសេនីយ៍ឯក Sanders (ម្ចាស់ហាងមាន់បំពង Kentucky Fried Chicken) ជាថ្នាក់លើម្នាក់របស់គាត់ បានរៀបរាប់មិត្តភក្តិច្រើនថា ជាសមាជិកសេអ៊ីអាដែលជួយបណ្តុះបណ្តាលគាត់អំពីការស៊ើបការណ៍របស់សេអ៊ីអា ហើយ "លោក S. Tarr" ជាគ្រូបង្រៀនជំនាញការថ្លែងជាសាធារណៈ។ តាមពិត S. Tarr ជាឈ្មោះម្តាយលោក គឺអ្នកស្រី Esther តែប៉ុណ្ណោះ[៦]។ ចម្លើយសារភាពរបស់ Kerry ត្រូវបានចុះហត្ថលេខា ប្រហែលពីរខែក្រោយពេលគាត់ត្រូវគេចាប់ខ្លួន ហើយមានការសន្និដ្ឋានថាគាត់ត្រូវបានគេសម្លាប់ នៅអំឡុងពេលចុះហត្ថលេខាលើចម្លើយសារភាពនោះឯង។ វិធីសាស្ត្រពិតប្រាកដជាក់ស្តែងក្នុងការសម្លាប់ Kerry មិនត្រូវបានគេដឹងទេ[៧]។

២. អង្គហេតុដែលលោក Robert Hamill បានលើកឡើង នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១១ សុទ្ធតែជាអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី១[៨] ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ រួចហើយគឺ៖

- សេចក្តីសង្ខេប នៃអង្គហេតុ (កថាខណ្ឌទី១ ដល់ ទី៣៦)
- ការជម្លៀសដោយបង្ខំ (កថាខណ្ឌទី ៣៧ ដល់ ទី ៤២)
- ការធ្វើពលកម្មដោយបង្ខំ ស្ថានភាពរស់នៅអមនុស្សធម៌ និងការឃុំខ្លួនដោយខុសច្បាប់ (កថាខណ្ឌទី ៤៣ ដល់ ទី ៤៨)
- ការសម្លាប់ ការធ្វើទារុណកម្ម និងការរំលោភបំពានផ្នែករាងកាយ និងផ្លូវចិត្ត ( កថាខណ្ឌទី ៤៩ និង ទី ៥៥ ) តំបន់ភ្នំពេញ។
- តំបន់ស្វាយ៉ត កំពង់សោម (កថាខណ្ឌទី ៥៩)
- ភូមិភាគឧត្តរចាស់ ភូមិភាគបូព៌ា។

ព្រមទាំងនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស[៩]។

---

[៦] កថាខណ្ឌទី ២៩ នៃបណ្តឹងឧទ្ធរណ៍ D5/2/4/2។

[៧] កថាខណ្ឌទី ៣០ ៖ នៃបណ្តឹងឧទ្ធរណ៍ D5/2/4/2។

[៨] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លេខ D3។

[៩] ដីកាដំណោះស្រាយ D427 កថាខណ្ឌទី ២២១ ដល់ ២៨២ និងកថាខណ្ឌទី ៦៤៤ ដល់ ៦៦៦។

00778584



៣. ម្យ៉ាងទៀត យើងយល់ឃើញថា អង្គហេតុដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលបង្កើតបានជាសំណុំរឿង ០០៤ សុទ្ធតែអង្គហេតុចាស់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧។

៤. នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររបស់ខ្លួនក្នុងសំណុំរឿង០០៤ រហូតមកដល់ពេលនេះ សហចៅក្រមស៊ើបអង្កេតមិនទាន់បានដាក់ជនណាម្នាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនោះទេ។ នេះមានន័យថា ក្នុងអង្គហេតុ ដែលសហព្រះរាជអាជ្ញាបញ្ជូនមកសហចៅក្រមស៊ើបអង្កេតតាមរយៈដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរនោះ គ្មានជនសង្ស័យណាម្នាក់ដែលសហចៅក្រមស៊ើបអង្កេតរកឃើញថាមានតម្រុយជាក់លាក់ និងស៊ីសង្វាក់ថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់នោះទេ។

៥. ដូច្នេះ ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងដំណាក់កាលនេះមិនធ្វើឱ្យប៉ះពាល់សិទ្ធិ អ្នកដាក់ពាក្យសុំ លោក Robert Hamill ឡើយ។ លើសពីនេះទៅទៀត យើងយល់ឃើញថា៖

៦. តាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ គឺសហព្រះរាជអាជ្ញាត្រូវធ្វើការវិនិច្ឆ័យលើអង្គហេតុដែលមានលក្ខណៈជាបទល្មើស និងមានជម្រើសថា តើត្រូវធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកមិនចាត់ការ ទោះបីអង្គហេតុនោះជាបទល្មើសក៏ដោយ។ តាមគោលការណ៍នេះ សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរ តាមអង្គហេតុដែលសហព្រះរាជអាជ្ញាប្ដឹងមកខ្លួន ដោយធ្វើការវាយតម្លៃលើភស្តុតាងដាក់បន្ទុកទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានបញ្ជូនមកភ្ជាប់ជាមួយនឹងសំណុំរឿង និងភស្តុតាងដោះបន្ទុកដែលខ្លួនទទួលបានបន្ថែមទៀត នៅក្នុងពេលដែលខ្លួនបានធ្វើការស៊ើបសួរព្រមទាំងភាពស៊ីសង្វាក់ដែលសង្ស័យថា បុគ្គលណាមួយបានប្រព្រឹត្តបទល្មើស។ ជាក់ស្ដែង មាត្រា ៥៥(២) នៃវិធានផ្ទៃក្នុង តម្រូវឱ្យសហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការស៊ើបសួរតែអង្គហេតុណាដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

៧. វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង ដែលចែងថា សហចៅក្រមស៊ើបអង្កេត ***មានអំណាចបើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។*** សហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួរផងដែរ ចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និង ស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុង

00778585



ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលទាំងនោះមិនមានឈ្មោះក្នុងដីកាក៏ដោយ។ ក្នុងករណីចុងក្រោយនេះ សហចៅក្រមស៊ើបអង្កេតត្រូវសួរយោបល់សហព្រះរាជអាជ្ញា មុនពេលដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យ។

៨. ពាក្យថា "*មានអំណាចបើកការស៊ើបសួរ*" នៅក្នុងវិធាន **៥៥(៤)** នេះ បង្ហាញច្បាស់ថា វិធានបានផ្ដល់ឆន្ទានុសិទ្ធិឱ្យសហចៅក្រមស៊ើបអង្កេត ក្នុងការសម្រេចដាក់អោយស្ថិតក្រោមការពិនិត្យរបស់ខ្លួននូវជនទាំងឡាយដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងមានអំណាចបើកការស៊ើបសួរផងដែរ ចំពោះជនផ្សេងទៀត ដែលគ្មានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ បញ្ញត្តិនេះមិនបានចាប់បង្ខំឱ្យសហចៅក្រមស៊ើបអង្កេត ត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញានោះទេ។ ម្យ៉ាងទៀត ***តាមមាត្រា ៥៥ (៥)*** ក៏គ្រាន់តែទុកសិទ្ធិឱ្យសហចៅក្រមស៊ើបអង្កេតសម្រេចថា តើគួរកោះហៅ ឬមិនកោះហៅ ជនសង្ស័យ ឬជនត្រូវចោទមកស្ដួចម្លើយតែប៉ុណ្ណោះ។

៩. មានន័យថា នៅពេលដែលសហព្រះរាជអាជ្ញាបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយស្នើសុំដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ឬស្នើសុំឱ្យឃុំខ្លួនបណ្ដោះអាសន្នលើឈ្មោះបុគ្គលណាមួយជាក់លាក់នោះ សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិក្នុងការសម្រេចដាក់ ឬ មិនដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យ ឬឃុំខ្លួនបណ្ដោះអាសន្ន។ ដូច្នេះ ចំពោះឈ្មោះជនត្រូវចោទដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះសហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ចធ្វើតាមអ្វីដែលសហព្រះរាជអាជ្ញាប្ដឹងមកនោះទេ។ ដូច្នេះការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យជាសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត។

១០. តាមវិធាន ៥៧ (១)៖ នៅពេលជនត្រូវចោទចូលបង្ហាញខ្លួន ចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និងប្រាប់ជននោះអំពីបទចោទប្រកាន់ និងអំពីសិទ្ធិមានមេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ។ បញ្ញត្តិនេះ គ្រាន់តែបញ្ញត្តិអំពីសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទតែប៉ុណ្ណោះ (***សិទ្ធិទទួលដំណឹងពីបទចោទប្រកាន់ សិទ្ធិមានមេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ***) នៅពេលដែលខ្លួនត្រូវមកបង្ហាញខ្លួន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ទោះបីជាបង្ហាញខ្លួនដោយខ្លួនឯងតាមរយៈដីកា

00778586



បង្គាប់ឱ្យចូលខ្លួន ឬដោយបង្ខំ តាមរយៈដីកាបង្គាប់ឱ្យចាប់ខ្លួនក៏ដោយ។ បញ្ញត្តិនេះមិនតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតដាច់ខាតត្រូវតែធ្វើការបង្គាប់ឱ្យជនត្រូវចោទចូលមកបង្ហាញខ្លួន នៅពេលសហចៅក្រមស៊ើបអង្កេតបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ ពោលគឺមិនកំណត់ថា នៅពេលណាមួយជាក់លាក់នោះឡើយ។

១១. ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ គឺធ្វើឡើងប្រឆាំងចំពោះបុគ្គលណាម្នាក់នៅពេលដែលសហចៅក្រមស៊ើបអង្កេតមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់យ៉ាងខ្លាំងថា ជននោះបានចូលរួមប្រព្រឹត្តបទល្មើស ក្នុងឋានៈជាចារី ឬ ជាអ្នកសមគំនិត។

១២. ដូចដែលបានលើកក្នុងកថាខណ្ឌទី ៤ ខាងលើ នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររបស់ខ្លួន ក្នុងសំណុំរឿង ០០៤ រហូតមកដល់ពេលនេះ សហចៅក្រមស៊ើបអង្កេតមិនទាន់បានដាក់ជនណាម្នាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនោះទេ មានន័យថា ក្នុងអង្គហេតុដែលសហព្រះរាជអាជ្ញាបញ្ជូនមកសហចៅក្រមស៊ើបអង្កេត តាមរយៈដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរនោះ គ្មានជនសង្ស័យណាម្នាក់ដែលសហចៅក្រមស៊ើបអង្កេតរកឃើញថាមានតម្រុយជាក់លាក់ និងស៊ីសង្វាក់ថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់នោះទេ។

១៣. យោងតាមការបកស្រាយខាងលើ យើងយល់ឃើញថា មកទល់នឹងពេលចេញដីកាដែលរងការប្តឹងជំទាស់នឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យសុំ លោក Robert Hamill ក្នុងសំណុំរឿង ០០៤ នេះ អង្គហេតុដែលបានប្តឹងមកសហចៅក្រមស៊ើបអង្កេត តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ សហចៅក្រមស៊ើបអង្កេតមិនទាន់អាចកំណត់ឈ្មោះជនត្រូវចោទបាននៅឡើយ។

១៤. ម្យ៉ាងទៀត ការប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីធ្វើឡើងក្នុងគោលបំណងឱ្យទទួលបាននូវការជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ។ អំពើល្មើសនោះ ត្រូវកើតឡើងដោយផ្ទាល់ពីអំពើរបស់ជនល្មើស រួមមាន ចារី សហចារី។ល។

00778587



១៥. យើងយល់ឃើញថា កាលបើពុំមានជនត្រូវចោទដែលត្រូវទទួលខុសត្រូវក្នុងការជួសជុលការខូចខាតបណ្តាលមកពីអំពើល្មើសរបស់ខ្លួនលើជនរងគ្រោះទេនោះ ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងដំណាក់កាលនេះ មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិជនរងគ្រោះឡើយ។[១០]

ភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២

ប្រាក់ គឹមសាន ន័យ ចុល ហួត វុទ្ធី

[១០] វិធាន ២៣ ស្ទួនបួន នៃវិធានផ្ទៃក្នុង។

# មតិយោបល់របស់ចៅក្រម LAHUIS និង ចៅក្រម DOWNING

## ១. សេចក្ដីសង្កេតបឋមលើគោលការណ៍តម្លាភាព និងគោលការណ៍បដិបក្ខផ្នែកកិច្ចនីតិវិធី

១. តាំងពីដំបូងមក យើងកត់សម្គាល់ឃើញថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ និងយ៉ាងហោចណាស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត[1] ដែលពាក្យសុំរបស់ខ្លួនត្រូវបានចុះបញ្ជីនៅក្នុងសំណុំរឿង ០០៤[2] នៅពេលមានការដាក់បណ្ដឹងឧទ្ធរណ៍[3] បានជួបនឹងបញ្ហាស្រដៀងៗគ្នា មិនខុសពីបញ្ហា ដែលយើងបានរកឃើញនៅក្នុងសំណុំរឿង ០០៣[4] នៅពេលពួកគេដាក់បណ្ដឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ខ្លួន នៅចំពោះមុខ អ.វ.ត.ក និងនៅពេលពួកគេស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតពិនិត្យ និងចាត់ការលើបណ្ដឹង និងពាក្យសុំរបស់ខ្លួន ដោយគោរពគោលការណ៍តម្លាភាព និងគោលការណ៍បដិបក្ខ។ យើងនឹងបង្ហាញដោយសង្ខេបនូវបរិបទ ដែលពាក្យសុំរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍[5] ត្រូវបានដាក់ និងសម្រេចដោយសហចៅក្រមស៊ើបអង្កេត។ មានផលវិបាកដោយជៀសមិនរួចលើវិធីសាស្ត្រ ដែលយើងយកមកប្រើដើម្បីបង្កើតមតិយោបល់របស់យើងលើបញ្ហានេះដោយម្ចាស់បណ្ដឹងឧទ្ធរណ៍ និងមេធាវីតំណាងរបស់ខ្លួន ដែលពុំមានលទ្ធភាពពិនិត្យសំណុំរឿង ពុំបានដឹងចំពោះករណីនេះ។

---

[1] ទម្រង់ពត៌មានជនរងគ្រោះ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ D5/1។

[2] បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert Hamill (D11/2/3) (សំណុំរឿងលេខ ០០២ និង ០០៣) ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D5/2/4/2 ("បណ្ដឹងឧទ្ធរណ៍")។

[3] នៅក្នុងសេចក្ដីប្រកាសពត៌មាន ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតលើកឡើងថា ពួកគាត់បានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចំនួន ២០០ ប៉ុន្តែ មានតែពាក្យបណ្ដឹងចំនួនពីរប៉ុណ្ណោះ ដែលត្រូវបានដាក់ក្នុងសំណុំរឿង នៅពេលបណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់ ហើយពាក្យសុំនេះ ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងបានតែពីរ ឬបីថ្ងៃ ឬ ពីរ ឬបីនាទីប៉ុណ្ណោះ មុនពេលពាក្យសុំនោះត្រូវបានបដិសេធវិញ។

[4] សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ D11/2/4/4 មតិយោបល់របស់ចៅក្រម Lahuis និង Downing ("មតិយោបល់នៅក្នុងសំណុំរឿង ០០៣") កថាខណ្ឌ ២-៩។

[5] ទម្រង់ពាក្យសុំជនរងគ្រោះ ចុះហត្ថលេខា នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ និងត្រូវបានដាក់ទៅឱ្យអង្គភាពគាំពារជនរងគ្រោះ នៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១១ D5/2 ("ពាក្យសុំ")។

២. ជាបឋម ជាលទ្ធផលនៃការពន្យារពេលយ៉ាងយូរដោយពុំបានពន្យល់ហេតុផល ចំពោះការពិនិត្យលើឯកសារទាំងឡាយ ដែលអ្នកដាក់ពាក្យសុំ ឬ ភាគីនៃកិច្ចដំណើរការនីតិវិធីបានដាក់នៅក្នុងសំណុំរឿង ០០៤ និងចំពោះការដាក់បញ្ចូលឯកសារទាំងនេះនៅក្នុងសំណុំរឿង ពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេតដាក់ចូលទៅក្នុងសំណុំរឿង ក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពីការិយាល័យនេះបានទទួលពីអង្គភាពគាំពារជនរងគ្រោះ និងក្នុងរយៈពេលតែប៉ុន្មាននាទីតែប៉ុណ្ណោះ មុនពេលការិយាល័យនេះសម្រេចបដិសេធឯកសារទាំងអស់នេះចោលនៅក្នុងដីកាសម្រាប់សំណុំរឿង ០០៤[៦]។ ដូចបានកត់សម្គាល់នាពេលមុនៗរួចមកហើយ នៅក្នុងសំណុំរឿង០០៣ និងសម្រាប់ហេតុផលដែលពន្យល់នៅពេលនេះ ការដាក់ឯកសារពាក់ព័ន្ធនឹងពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងលក្ខណៈយឺតយ៉ាវដូច្នេះ អាចចាត់ទុកថា វាជាការព្យាយាមរារាំងមិនឱ្យមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ មានលទ្ធភាពពិនិត្យសំណុំរឿង ក្នុងសំណុំរឿង ០០៤[៧]។ ម្យ៉ាងវិញទៀត ទោះបីជាឯកសារនេះគឺជាបណ្តឹងក៏ដោយ ឯកសារនេះទំនងជាមិនបានបញ្ជូនបន្តភ្លាមៗទៅឱ្យសហព្រះរាជអាជ្ញា តាមលក្ខខណ្ឌតម្រូវនៃវិធាន ៤៩(២) នៃវិធានផ្ទៃក្នុង ដើម្បីធ្វើចំណាត់ការនៅឡើយទេ។

៣. ចំណុចទីពីរ សហមេធាវី ដែលបានដាក់លិខិតតំណាងដោយអាណត្តិ នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១១[៨] បានទទួលដំណឹងនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ ថា ខ្លួនពុំទាន់ត្រូវបានសហចៅក្រម

---

[៦] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ទោះបីជាត្រូវបានទទួលដោយមន្ត្រីគ្រប់គ្រងសំណុំរឿង នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១ ហើយចុះនៅក្នុងប្រព័ន្ធ Zylab ដូចដែលបានដាក់នៅក្នុងកាលបរិច្ឆេទនេះ ត្រូវបានដាក់ក្នុងសំណុំរឿង នៅថ្ងៃទី ២៩ ខែ មេសា នៅវេលាម៉ោង ១៤:៤០ នាទី ពោលគឺ ៣០ នាទី មុនពេលដាក់ដីកាដែលត្រូវបានជំទាស់ នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ នៅម៉ោង ១៥:១០ នាទី។ ឯកសារមួយចំនួនដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងរឿងក្តីនេះ ក៏ត្រូវបានពន្យារពេលដែរ។

[៧] យើងយល់ឃើញថា វិធាន ២៣*ស្ទួន*(២) នៃវិធានផ្ទៃក្នុង នៅពេលយកមកពិចារណារួមជាមួយនឹងវិធាន ៥៥(៦) និង(១១) នៃវិធានផ្ទៃក្នុង វិធាននេះបានផ្តល់ឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិពិនិត្យសំណុំរឿង តាមរយៈមេធាវីតំណាងរបស់ខ្លួន ចាប់តាំងពីពេលដែលពាក្យសុំនេះបានដាក់រហូតដល់ពេលដីកាសម្រេចបដិសេធពាក្យសុំចូលជាស្ថាពរ។ មតិយោបល់នៅក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៦។ ដូច្នេះ យើងបានបង្ហាញមតិទស្សនៈរបស់យើងនាពេលមុនរួចហើយថា ការដាក់ឯកសារពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីយឺតយ៉ាវ អាចចាត់ទុកថា វាជាការព្យាយាមដកហូតសិទ្ធិរបស់អ្នកដាក់ពាក្យសុំ ក្នុងការពិនិត្យសំណុំរឿង៖ មតិយោបល់នៅក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៩។

[៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥។

ស៊ើបអង្កេតទទួលស្គាល់នៅឡើយទេ[9] ទោះបីជាពួកគេត្រូវបានទទួលស្គាល់ នៅក្នុងសំណុំរឿង ០០២ ដោយអនុលោមតាមវិធាន ២២ រួចហើយក៏ដោយ។ ស្ថានភាពបែបនេះនៅតែពុំមានការប្រែប្រួលនៅឡើយ បើយោងតាមពត៌មានដែលអង្គបុរេជំនុំជម្រះមាន។ ដោយសារហេតុនេះហើយ ទើបសហមេធាវីពុំទទួលបានការជូនដំណឹងអំពីឯកសារណាមួយ ទាក់ទិននឹងពាក្យសុំ ដែលខ្លួនបាន ដាក់ក្នុងនាមកូនក្តីរបស់ខ្លួន ក្នុងនោះរួមទាំងដីកាសម្រេចក្នុងសំណុំរឿង ០០៤ ផងដែរ ជាហេតុធ្វើឱ្យប៉ះពាល់លើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការតំណាងតាមផ្លូវច្បាប់។

៤. ចំណុចទីបី សំណើសុំពិនិត្យសំណុំរឿង ដែលសហមេធាវី[10] បានដាក់ម្តងហើយម្តងទៀតនោះ នៅតែពុំទាន់បានទទួលការឆ្លើយតបមកវិញពីសហចៅក្រមស៊ើបអង្កេតនៅឡើយ ដូច្នេះ សហមេធាវីពុំទាន់មានលទ្ធភាពពិនិត្យសំណុំរឿងនៅឡើយ[11]។ ស្ថានភាពនេះ បានជំរុញឱ្យសហមេធាវីដាក់សំណើសុំពិនិត្យសំណុំរឿងដែលខ្លួនបានលើកឡើង ទៅអង្គបុរេជំនុំជម្រះ ដើម្បីធ្វើយ៉ាងណាអាចឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍មានលទ្ធភាពអនុវត្តសិទ្ធិប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ មិនខុសពីសំអាងហេតុដែលយើងបានបង្ហាញមតិយោបល់របស់យើង នៅក្នុងសំណុំរឿង០០៣[12] យើងគាំទ្រចំពោះការអនុញ្ញាតតាមសំណើសុំពិនិត្យសំណុំរឿង ហើយអនុញ្ញាតឱ្យសហមេធាវីដាក់សារណាលើបណ្តឹងឧទ្ធរណ៍បន្ថែមទៀតបាន ក៏ប៉ុន្តែដោយហេតុថា អង្គបុរេជំនុំជម្រះពុំមានលទ្ធភាពរកសំឡេងគាំទ្រជាវិជ្ជមានចំនួន៤ សំឡេងនោះ ពុំមានការសម្រេចណាមួយលើបញ្ហានេះ ត្រូវបានធ្វើឡើងនោះទេ ។

៥. ចំណុចទីបួន ពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ពិនិត្យ និងច្រានចោលដោយសហ-ចៅក្រមស៊ើបអង្កេត ដោយពុំបានអនុញ្ញាតឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍មានលទ្ធភាពពិនិត្យព័ត៌មានណាមួយអំពីវិសាលភាពនៃកិច្ចស៊ើបសួរនោះទេ។ ហេតុដូច្នេះ វាបានធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នៅក្នុងការអនុវត្តសិទ្ធិធ្វើបណ្តឹងដោយមានប្រសិទ្ធភាព និងបង្ហាញភស្តុតាង

---

[9] សៀវភៅចុះបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D5/2/4។

[10] សំណើសុំពន្យារកាលបរិច្ឆេទកាលកំណត់សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍ ជំទាស់នឹងដីកាស្តីពីភាពអាចទទួលយកបានចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ក្នុងពេលកំពុងរង់ចាំការអនុញ្ញាតឱ្យពិនិត្យមើលសំណុំរឿង ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ ដាក់នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D5/2/4/1។

[11] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦។

[12] មតិយោបល់នៅក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៦។

ដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង។ ជាពិសេស ពុំមានព័ត៌មានណាមួយទាល់តែសោះអំពីវិសាលភាពនៃកិច្ចស៊ើបសួរ បានផ្តល់ជូនសាធារណជន ជនរងគ្រោះ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីសក្តានុពល រួមបញ្ចូលទាំងម្ចាស់បណ្តឹងផង នៅពេលម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់ពាក្យសុំ និងបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ ជាពិសេស ក្រោយពីបានដាក់ពាក្យសុំរបស់ខ្លួន ម្ចាស់បណ្តឹងឧទ្ធរណ៍ ពុំទទួលបានលទ្ធភាពពិនិត្យសំណុំរឿង ហើយក៏ពុំទទួលបានព័ត៌មាន ទោះក្នុងវិធីណាក៏ដោយ អំពីវិសាលភាពនៃកិច្ចស៊ើបសួរ នៅមុនពេលពាក្យសុំរបស់ខ្លួនត្រូវបានច្រានចោលនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ រួមជាមួយនឹងពាក្យសុំរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ដែលត្រូវបានចុះបញ្ជីនៅក្នុងរឿងក្តីនេះរួចហើយនោះ[១៣]។ សហចៅក្រមស៊ើបអង្កេតបានត្រឹមតែលាតត្រដាងព័ត៌មាន អំពីវិសាភាពនៃកិច្ចស៊ើបសួរ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ ២០១១ តែប៉ុណ្ណោះ ដោយបានពន្យល់ថា៖

> "មកត្រឹមពេលនេះ ការិយាល័យសហចៅក្រមស៊ើបអង្កេតនៅពុំទាន់បានជូនដំណឹងដល់សាធារណជនអំពីទីតាំងបទល្មើសនៅក្នុងសំណុំរឿង ០០៤ នៅឡើយទេ ដោយហេតុថា ខុសពីសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតនៅមានវិមតិសង្ស័យយ៉ាងខ្លាំងនៅឡើយ ថាតើជនសង្ស័យទាំងនេះ "គឺជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ស្របតាមលក្ខខណ្ឌយុត្តាធិការនៃមាត្រា ២ នៃច្បាប់ អ.វ.ត.ក ដែរឬទេ។ ប្រសិនបើតុលាការនេះពុំមានយុត្តាធិការទេនេះ វានឹងពុំមានភាពសមស្របក្នុងការលើកទឹកចិត្តឱ្យដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បន្ថែមលើពាក្យសុំចំនួន ២០០ ពាក្យសុំ ដែលបានដាក់រួចមកហើយនៅក្នុងរឿងក្តីនេះឡើយ។ បញ្ហានេះអាចនឹងបង្កើតជាក្តីសង្ឃឹមដែលនឹងមិនអាចបំពេញទៅតាមបាននាពេលក្រោយមក"[១៤]។

ដូចអង្គបុរេជំនុំជម្រះបានគូសបញ្ជាក់រួចស្រាប់ហើយនៅក្នុង "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" នៅក្នុងសំណុំរឿង ០០២[១៥] និងលើកឡើងម្តងទៀតនៅក្នុងមតិយោបល់

---

[១៣] ដីកាសម្រេចស្តីពីភាពអាចទទួលយកបានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D5/1/3។

[១៤] សេចក្តីប្រកាសព័ត៌មាន របស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹង ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ (០០៤/០៧-០៩-២០០៩/កសចស) ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១១។

[១៥] សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ D404/2/4 និង D411/3/6 កថាខណ្ឌរួម ៥១-៥៤។

របស់យើងដោយឡែក ដែលយើងបានផ្ដល់ជូននៅក្នុងសំណុំរឿង ០០៣[១៦] ការលាតត្រដាងព័ត៌មានឱ្យបានគ្រប់គ្រាន់អំពីវិសាលភាពនៃកិច្ចស៊ើបសួរ ក្នុងលក្ខណៈមួយទាន់ពេលវេលា គឺមានសារៈសំខាន់ណាស់ នៅក្នុងការអនុញ្ញាតឱ្យជនរងគ្រោះអនុវត្តសិទ្ធិ ក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ស្របតាមវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថា ខែ មេសា ឆ្នាំ ២០១១ គឺជាពេលវេលាឆាប់ពេក ក្នុងការលាតត្រដាងអំពីវិសាលភាពនៃកិច្ចស៊ើបសួរ ដូច្នេះ វិធានផ្ទៃក្នុងតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតរង់ចាំរហូតទាល់តែពត៌មាននេះត្រូវបានលាតត្រដាង និងពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានដាក់នៅចំពោះមុខពួកគាត់ ត្រូវមានឯកសារបន្ថែមគ្រប់គ្រាន់ ដូចដែលសហចៅក្រមស៊ើបអង្កេតបានអនុវត្តចំពោះម្ចាស់បណ្ដឹងឧទ្ធរណ៍ ។ តាមទស្សនៈរបស់យើង ការបំពេញកិច្ចណាមួយផ្សេងពីនេះនឹងបង្កើតជាការសម្រេចបដិសេធមុនកាលបរិច្ឆេទកំណត់លើពាក្យសុំ ហើយនឹងធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធទាំងមូល ដែលបានបង្កើតឡើងសម្រាប់ជនរងគ្រោះ ស្របតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ ដោយពិចារណាលើការសម្រេចបដិសេធមុនកាលបរិច្ឆេទកំណត់លើពាក្យសុំ និងដោយពិចារណាលើករណីដែលថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ពុំទទួលបានលទ្ធភាពក្នុងការដាក់ព័ត៌មានបន្ថែមលើពាក្យសុំ ដែលនៅទីបំផុតព័ត៌មានទាំងនេះត្រូវបានលាតត្រដាងនៅក្នុងខែ សីហា ឆ្នាំ ២០១១ មក យើងយល់ឃើញថា ពុំមានអ្វីអាចនឹងរារាំងម្ចាស់បណ្ដឹងឧទ្ធរណ៍មិនឱ្យដាក់ពាក្យសុំថ្មីមួយឡើយ ប្រសិនបើម្ចាស់បណ្ដឹងឧទ្ធរណ៍យល់ឃើញថា វាសមស្រប ផ្អែកតាមព័ត៌មានដែលទើបតែមានក្នុងពេលនេះនោះ។ សេចក្ដីសន្និដ្ឋាននេះត្រូវបានធ្វើឡើង ដោយមិនគិតថាតើពាក្យសុំរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ឆ្លើយតប ឬមិនឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យដែលជាមូលដ្ឋាននៅពេលនោះ សម្រាប់ទទួលយកដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤ ដោយអនុលោមតាមវិធាន ២៣ *ស្ទួន* នៃវិធានផ្ទៃក្នុង។

៦. យើងកត់សម្គាល់ឃើញបន្ថែមទៀតថា ចំពោះការពន្យល់ហេតុផលដោយសហចៅក្រមស៊ើបអង្កេតដើម្បីផ្ដល់យុត្តិកម្មលើការពន្យារពេលផ្ដល់ព័ត៌មានអំពីកិច្ចស៊ើបសួរដល់ជនរងគ្រោះ និងអ្នកដាក់ពាក្យសុំដែលទំនងអាចនឹងក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណី គឺជាការពន្យល់ដែលពុំមានហេតុផលរឹងមាំទៅតាមផ្លូវច្បាប់នោះទេ ។ ដូចយើងបានលើកឡើងដោយសង្កត់ធ្ងន់ នាពេលមុនរួចមកហើយថា ការដែលសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា អ.វ.ត.ក ទំនងជាមិនអាចមានយុត្តាធិការ

---

[១៦] មតិយោបល់នៅក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៤។

00778593



បុគ្គលក្នុងការចោទប្រកាន់បុគ្គល ដែលត្រូវបានចោទប្រកាន់ថាជាចារី ឬអ្នកសមគំនិតដូចមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣នោះ ពុំបានធ្វើឱ្យសហចៅក្រមស៊ើបអង្កេតរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការបំពេញកិច្ចស៊ើបសួរទៅលើអង្គហេតុដែលបានចោទប្រកាន់ចំពោះអ្នកទាំងនោះ ដូចមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ ដើម្បីបំពេញកិច្ចស៊ើបសួរឱ្យបានពេញលេញ និងមិនលម្អៀង ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ ដូចបានណែនាំដោយវិធាន ៥៥(១)នៃវិធានផ្ទៃក្នុង[១៧]។ ក្នុងន័យនេះ យើងរំឭកថាជនរងគ្រោះមិនថា ក្នុងនាមគាត់ជាអ្នកដាក់ពាក្យបណ្តឹង[១៨] និង/ឬ ជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ អាចអនុវត្តសិទ្ធិរបស់ខ្លួន និងអាចចូលរួមក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ ដែលត្រូវបានធ្វើឡើងនៅចំពោះមុខ អ.វ.ត.ក[១៩] ដែលអាចយកពត៏មានដែលនាំដល់ការបញ្ជាក់ការពិត រួមទាំងព័ត៏មានដែលពាក់ព័ន្ធ និងអាចមានអានុភាព នៅពេលសម្រេចលើយុត្តាធិការលើបុគ្គលរបស់តុលាការលើអ្នកដែលត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ហេតុដូច្នេះ នៅពេលបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការ ដូចជាក្នុងករណីនៃសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមគោលការណ៍ នឹងត្រូវផ្តល់ឱ្យជនរងគ្រោះទទួលបានលទ្ធភាពយ៉ាងមានប្រសិទ្ធិភាព និងប្រសិទ្ធិផល ក្នុងការដាក់ពាក្យបណ្តឹង និង/ឬ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងនិយាយឱ្យទូទៅជាងនេះ គឺលទ្ធភាពក្នុងការចូលរួមនៅក្នុងកិច្ចស៊ើបសួរ ប្រសិនបើពួកគេបានបំពេញតាមលក្ខខណ្ឌច្បាប់ ដូចបានកំណត់នៅក្នុងវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង។

៧. នៅក្នុងបរិបទ ដែលកង្វះតម្លាភាពនៃកិច្ចដំណើរការនីតិវិធី បានបង្កការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិរបស់

---

[១៧] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹងសេចក្តីសម្រេចស្តីពីការដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទាំងបីឡើងវិញ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ D26/1/3 មតិយោបល់របស់ចៅក្រម Lahuis និង Downing កថាខណ្ឌ ១៦-១៨។

[១៨] វិធាន៤៩ នៃវិធានផ្ទៃក្នុង ។

[១៩] សូមមើល សិទ្ធិបានផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ ក្រោមវិធាន ៥៥(៨) (ចុះដល់ទីកន្លែងកើតហេតុដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត) វិធាន ៥៥(១០) (សំណើបំពេញកិច្ចស៊ើបសួរ) វិធាន ៥៥(៥) (ចូលរួមក្នុងករណីតទល់គ្នា) វិធាន ៥៩(៥) (អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះដល់ទីកន្លែងកើតហេតុ បង្គាប់ឱ្យធ្វើកោសល្យវិច័យ ឬ ប្រមូលយកភស្តុតាងដទៃទៀត វិធាន ៧៤(៤) (បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត) និង ៧៦(២) (ស្នើសុំមោឃៈភាពនៃផ្នែកណាមួយនៃនីតិវិធី)។

00778594



ម្ចាស់បណ្ដឹងឧទ្ធរណ៍ ក្នុងការបង្ហាញរឿងក្ដីរបស់ខ្លួនឱ្យបានល្អបំផុត មិនត្រឹមតែពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ខ្លួនប៉ុណ្ណោះទេ វាថែមទាំងប៉ះពាល់លើបណ្ដឹងឧទ្ធរណ៍របស់ខ្លួននៅចំពោះមុខអង្គបុរេជំនុំជម្រះ ដែលជាបរិបទនេះជំរុញឱ្យយើងដោះស្រាយបញ្ហាជាក់លាក់នៃការជូនដំណឹងអំពីដីកាសម្រេច ក្នុងសំណុំរឿង ០០៤ ដល់ម្ចាស់បណ្ដឹងឧទ្ធរណ៍ និង មេធាវីរបស់ខ្លួន។

## ២. សេចក្ដីជូនដំណឹងអំពីដីកា ក្នុងសំណុំរឿង ០០៤

៨. ដូចបានកត់សម្គាល់ដោយសង្ខេបនៅក្នុងប្រវត្តិនីតិវិធី សហមេធាវីបានចោទប្រកាន់ថា ខ្លួនបានទទួលការជូនដំណឹងតាមរយៈដីកាសម្រេចក្នុងសំណុំរឿង ០០៣[២០] អំពីការដែលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ក្នុងសំណុំរឿង០០៤ ត្រូវបានបដិសេធចោល ហើយខ្លួនបានទទួលការបញ្ជាក់បន្ថែមដោយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា ដីកាសម្រេចពុំទទួលយកពាក្យសុំ ដែលមានលេខឯកសារ D5/2/3 ត្រូវបានចេញដាច់ដោយឡែកមួយទៀតដោយយោងលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert Hamill សម្រាប់សំណុំរឿង ០០៤[២១]។ សហមេធាវីបានអះអាងថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ និងខ្លួនពុំបានទទួលដីកាសម្រេចបែបនេះ នៅពេលដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងឧទ្ធរណ៍ឡើយ[២២]។ ហេតុដូច្នេះ សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់ជា "សេចក្ដីជូនដំណឹងអំពីបំណង" ក្នុងការដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលេខ D5/2/3 "ប្រសិនបើ/នៅពេលដីកាសម្រេចនោះ" ត្រូវបានទទួល"[២៣] រួមជាមួយនឹងសំណើសុំលទ្ធភាពពិនិត្យសំណុំរឿងនៅក្នុងសំណុំរឿង ០០៤ និងសំណើសុំការអនុញ្ញាតដាក់ទឡ្ហីករណ៍បន្ថែមលើបណ្ដឹងឧទ្ធរណ៍ នៅក្នុងពេលវេលា

---

[២០] ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D11/2/3។

[២១] ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D5/2/3។

[២២] សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២។ បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣ និង ៤។ សូមមើលផងដែរ សំណើសុំ កថាខណ្ឌ ១ និង ២។

[២៣] សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣។

00778595



មួយសមស្របក្រោយពីទទួលបានសិទ្ធិពិនិត្យសំណុំរឿង[២៤]។ សហមេធាវីបានអះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍ថា "ការប៉ុនប៉ងជាច្រើនសា ដើម្បីទទួលបាន[ដីកាសម្រេចនៅក្នុងសំណុំរឿង ០០៤]" ត្រូវបានធ្វើឡើង[២៥]។ ទោះបីជាយ៉ាងនេះក្តី យើងកត់សម្គាល់ឃើញថា ការអះអាងនេះមិនទទួលបានការគាំទ្រដោយសេចក្តីយោងណាមួយ ឬ ដោយសេចក្តីពន្យល់ហេតុផលអំពីវិធានការ ដែលសហមេធាវី ឬម្ចាស់បណ្តឹងឧទ្ធរណ៍បានធ្វើឡើងដើម្បីទទួលបានដីកាសម្រេចនេះឡើយ។

៩. យើងកត់សម្គាល់ឃើញថា ចំពោះបញ្ហាទូទៅ វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅ អ.វ.ត.ក បង្គាប់ឡើងថា ក្រឡាបញ្ជី និង/ឬមន្ត្រីគ្រប់គ្រងសំណុំរឿងត្រូវ៖ i) កត់ត្រានៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមធ្យោបាយ ដែលបានប្រើប្រាស់នៅក្នុងការជូនដំណឹងនេះ ពេលវេលា ថ្ងៃខែឆ្នាំ ទីកន្លែង និងកាលៈទេសៈដទៃទៀត[២៦] ii) ខិតខំឱ្យអស់ពីលទ្ធភាព ដើម្បីប្រគល់ដីកា និងទទួលបានមកវិញនូវសេចក្តីបញ្ជាក់ទទួលស្គាល់ថាបានទទួលដីកា។ សេចក្តីបញ្ជាក់ទទួលស្គាល់ថាបានទទួលដីកានេះ ត្រូវដាក់ភ្ជាប់ទៅនឹងរបាយការណ៍នៃការបំពេញកិច្ចការ[២៧] និង iii) ត្រូវបំពេញទម្រង់បែបបទស្តីអំពី "ការទទួលស្គាល់នៃការជូនដំណឹង"[២៨] ដែលមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង ឬ មន្ត្រីដែលបានចាត់តាំងដោយផ្នែកគ្រប់គ្រងតុលាការ ត្រូវបញ្ជាក់អំពីការជូនដំណឹងអំពីឯកសារទៅដល់អ្នកទទួលរួចហើយ[២៩]។

១០. ចំពោះរឿងក្តីនេះ និងដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ០០៤ យើងពុំមានហេតុផលណាមួយអាចសន្និដ្ឋានថា ការអះអាងរបស់សហមេធាវីថា សហមេធាវី និងម្ចាស់បណ្តឹងឧទ្ធរណ៍ពុំទទួលបានការជូនដំណឹង ឬ ទទួលបានដីកាសម្រេចនៅក្នុងសំណុំរឿង ០០៤ គឺជាការអះអាងដោយមានកំហុសនោះឡើយ។ ជាបឋម សេចក្តីណែនាំឱ្យជូនដំណឹងដល់សហមេធាវីអំពី

---

[២៤] សំណើសុំ កថាខណ្ឌ ១-៤, ១២ និង ១៤។ ខ្លឹមសារនៃសំណើសុំនេះ ត្រូវបានយកមករៀបរាប់សាជាថ្មីនៅក្នុងបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៨។

[២៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤។

[២៦] វិធាន ៤៦(២) នៃវិធានផ្ទៃក្នុង។

[២៧] វិធាន ៤៦(៣) នៃវិធានផ្ទៃក្នុង។

[២៨] មាត្រា ១១.២ នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅ អ.វ.ត.ក។

[២៩] ឧបសម្ព័ន្ធ ង នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅ អ.វ.ត.ក។

ដីកាសម្រេចនេះ ពុំបានធ្វើឡើងឡើយ[៣០]។ ចំណុចទីពីរ ភស្តុតាងបង្ហាញអំពីការប្រគល់ដីកាសម្រេច ដែលមាននៅក្នុងសំណុំរឿង ពុំអាចឲ្យយើងសន្និដ្ឋានថា ម្ចាស់បណ្តឹងឧទ្ធរណ៍ ឬ សហមេធាវី ពិតជាត្រូវបានជូនដំណឹងអំពីដីកាសម្រេចនេះ[៣១]។ ចំណុចទីបី ដោយហេតុថា ម្ចាស់បណ្តឹងឧទ្ធរណ៍

---

[៣០] ទម្រង់បែបបទស្តីពីការណែនាំដាក់ឯកសារនៃដីកាដែលត្រូវបានជំទាស់ ដែលអង្គបុរេជំនុំជម្រះទទួលបានពីមន្ត្រីគ្រប់គ្រងសំណុំរឿង។

[៣១] កំណត់ហេតុបានបង្ហាញថា មន្ត្រីគ្រប់គ្រងសំណុំរឿង ដែលត្រូវបានណែនាំដោយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឲ្យជូនដំណឹងអំពីដីកាសម្រេចលេខ D5/2/3 (អង់គ្លេស) ដល់លោក Robert Hamill រួមជាមួយនឹងដីកាសម្រេចលេខ D11/2/3 ដែលត្រូវបានចេញសម្រាប់រឿងក្តី ០០៣ (ការដាក់ និងការណែនាំសេចក្តីជូនដំណឹងអំពីឯកសារលេខ D5/2/3 ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១)។ ការទទួលស្គាល់នៃការជូនដំណឹងអំពីដីកា ដែលត្រូវបានចុះហត្ថលេខាដោយផ្នែកសេវាកម្មទូទៅរបស់តុលាការ (ផ្នែកសេវាកម្មទូទៅ) លើកឡើងថា ការជូនដំណឹងអំពីដីកានេះ បានទទួល "ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D11/2/3 និង D5/2/3 (ភាសាអង់គ្លេស)" សម្រាប់ "រឿងក្តី ០០៣ និង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/កសចស" ដោយមិនមានការចង្អុលបញ្ជាក់ជាក់លាក់ ថាតើមានដីកាសម្រេចចំនួន ២ ខុសគ្នាដែរឬទេ។ ការទទួលស្គាល់នៃការជូនដំណឹងអំពីដីការួមមានកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដូចតទៅ៖ "លេខរបស់ក្រុមហ៊ុន TNT៖ gd996064631 ww" (ការទទួលស្គាល់នៃការជូនដំណឹងអំពីដីកា ដែលត្រូវបានចុះហត្ថលេខាដោយ [redacted] មកពីផ្នែកសេវាកម្មទូទៅ ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១១)។ បញ្ជាទិញរបស់ក្រុមហ៊ុន TNT ដែលត្រូវបានចុះហត្ថលេខាដោយមន្ត្រីគ្រប់គ្រងសំណុំរឿង រួមមានហត្ថលេខាចំនួន ២៖ ហត្ថលេខាមួយចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១១ និងហត្ថលេខាមួយទៀត ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១១។ ពុំមានហត្ថលេខាណាមួយទទួលស្គាល់ការទទួលបានលិខិតរបស់ក្រុមហ៊ុន TNT ដែលលិខិតនេះលើកឡើង "ជនបទ" សម្រាប់ហត្ថលេខី។ កំណត់ហេតុបញ្ជូនដោយក្រុមហ៊ុន TNT រួមមានការលើកឡើងចំនួនពីរដោយបង្ហាញថា ទំនិញ "៩៩៦០៦៤៦៣១" បានបញ្ជូនដល់ "យ៉ាងត្រឹមត្រូវ" នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១ នៅវេលាម៉ោង ០៨:៤០:00 និង ០៩:៤០:២៣ នៅ "North Island"។ ពុំមានការចង្អុលបង្ហាញថា ទំនិញនោះជាអ្វី ហើយអ្នកណាជាអ្នកទទួល។ ទោះបីជាការទទួលស្គាល់នៃការជូនដំណឹងអំពីដីកា មានគោលបំណងបញ្ជាក់នូវការជូនដំណឹងអំពីឯកសារជាក់លាក់ណាមួយទៅដល់បុគ្គល ដែលត្រូវបានទទួលការជូនដំណឹងអំពីដីកានេះក៏ដោយ ការទទួលស្គាល់នៅក្នុងរឿងក្តីនេះ ត្រឹមតែបង្ហាញថា ឯកសារមួយបានទទួលដោយ "បុគ្គលិករត់សំបុត្ររបស់ផ្នែកសេវាកម្មទូទៅ" ដែលមានតួនាទីត្រឹមតែបញ្ជូនឯកសារតាមរយៈក្រុមហ៊ុន TNT ក្រោយពីមន្ត្រីគ្រប់គ្រងសំណុំរឿងបានបំពេញបញ្ជាទិញរបស់ក្រុមហ៊ុន TNT រួចរាល់។ ឯកសារបែបនេះមិនអាចធ្វើជាភស្តុតាងនៃ*ការជូនដំណឹង* ឬ *ការទទួលបញ្ជាទិញលេខ D5/2/3* ដោយលោក Robert Hamill នៅក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើឡើយ។ ក្រៅពីនេះ យើងកត់សម្គាល់ឃើញថា នីតិវិធីមួយខុសពីធម្មតាត្រូវបានយកមកអនុវត្តនៅក្នុងរឿងក្តីនេះ ដោយមានឯកសារពីរខុសគ្នាបានចេញនៅក្នុងករណីពីរដាច់ដោយឡែកពីគ្នា ដែលត្រូវបានចង្អុលយោងនៅក្នុងការទទួលស្គាល់នៃការជូនដំណឹងតែមួយ។ ម្យ៉ាងវិញទៀត ផ្ទុយពីមាត្រា ១១.២ នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅ អ.វ.ត.ក និងទម្រង់បែបបទ ដែលដាក់ភ្ជាប់ជាមួយនឹងសេចក្តីណែនាំអនុវត្ត ទាំងក្រឡាបញ្ជី ទាំងមន្ត្រីដែលត្រូវបានចាត់តាំងនៅក្នុងរឿងក្តីនេះ ពុំបានទទួលស្គាល់ថា ដីកាសម្រេចត្រូវបានជូនដំណឹងដល់លោក ហាមីល ឡើយ។ ជាចុងក្រោយ ទម្រង់បែបបទដែលយកមកប្រើប្រាស់នៅក្នុងរឿងក្តីនេះ គឺខុសពីទម្រង់បែបបទ ដែលបានដាក់ភ្ជាប់នឹងសេចក្តីណែនាំអនុវត្ត ដែលចែងយ៉ាងច្បាស់ថា ក្រឡាបញ្ជី និងមន្ត្រីដែលត្រូវបាន

និងសហមេធាវី ពុំមានលទ្ធភាពពិនិត្យសំណុំរឿង ម្ចាស់បណ្ដឹងឧទ្ធរណ៍ និងសហមេធាវីទាំងនេះ ពុំអាចពិនិត្យមើលដីកាសម្រេចនេះបាន។ ចំណុចទីបួន សារណាទាំងឡាយដែលមាននៅក្នុង បណ្ដឹងឧទ្ធរណ៍ ខកខានមិនបានលើកឡើងសំអាងហេតុជាក់លាក់ចំពោះការបដិសេធ ដូចមាន រៀបរាប់នៅក្នុងដីកាសម្រេចនៅក្នុងសំណុំរឿង ០០៤[៣២] ដូច្នេះវាបញ្ជាក់យ៉ាងច្បាស់ថា បញ្ហានេះ មិនត្រូវបានលើកឡើងដោយម្ចាស់បណ្ដឹងឧទ្ធរណ៍ និងមេធាវីរបស់គាត់ឡើយ។

១១. អនុលោមតាមវិធាន ៤៦(១) នៃវិធានផ្ទៃក្នុង "រាល់ដីកាទាំងអស់របស់សហចៅក្រមស៊ើបអង្កេត [...] ត្រូវជូនដំណឹងដល់ភាគី ឬ មេធាវីរបស់ភាគីដោយផ្ទាល់មាត់ ឬ ផ្ញើទៅអាសយដ្ឋានចុង ក្រោយរបស់គេ បើអាចដឹងដោយក្រឡាបញ្ជី [...] តាមមធ្យោបាយសមស្រប"។ ដូចបានចង្អុល បង្ហាញខាងលើរួចហើយ ដីកាសម្រេចនៅក្នុងសំណុំរឿង ០០៤ យ៉ាងហោចណាស់ ត្រូវជូនដំណឹង ដល់មេធាវីរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍។ ហើយប្រសិនបើសេចក្ដីសម្រេចមួយបានធ្វើឡើងដើម្បីជូន ដំណឹងដល់ម្ចាស់បណ្ដឹងឧទ្ធរណ៍ តាមរយៈការជូនដំណឹងជាឯកសារក្រដាសមែននោះ ភស្តុតាងនៃ ការជូនដំណឹងប្រាកដជាបង្ហាញឱ្យយើងឃើញយ៉ាងគ្រប់គ្រាន់។ លក្ខខណ្ឌតម្រូវឱ្យធ្វើការជូនដំណឹង គឺមានគោលបំណងធានាថា ឯកសារទាំងឡាយដែលបានដាក់នៅក្នុងកិច្ចដំណើរការនីតិវិធី ត្រូវ ផ្ដល់ជូនដោយផ្ទាល់ទៅអ្នកទាំងឡាយ ដែលទទួលរងប៉ះពាល់ដោយកិច្ចដំណើរការនេះ ដើម្បីឱ្យ ពួកគេបានដឹង។ ទម្រង់បែបបទនេះពុំមែនមានភាពចាំបាច់ចំពោះសុចរិតភាពនៃកិច្ចដំណើរការនីតិ វិធីប៉ុណ្ណោះទេ វាក៏ជាគោលការណ៍សំខាន់នៃភាពយុត្តិធម៌ និងការដំណើរការនីតិវិធីត្រឹមត្រូវ ដោយហេតុថា វារារាំងស្ថាប័នតុលាការ មិនឱ្យដំណើរការដោយសម្ងាត់ពីភាគី និងបុគ្គលទាំងឡាយ ដែលទទួលរងប៉ះពាល់ដោយសេចក្ដីសម្រេចទាំងនេះ។ នៅក្នុងរឿងក្ដីនេះ ការជូនដំណឹងមានផល វិបាកផ្នែកច្បាប់យ៉ាងជាក់លាក់ នៅក្នុងការជំរុញលទ្ធភាពនៃការអនុវត្តសិទ្ធិប្ដឹងឧទ្ធរណ៍នៅដំណាក់

---

ចាត់តាំង ត្រូវបញ្ជាក់ថាទទួលបានការជូនដំណឹង បន្ទាប់ពី "អ្នកទទួល" មិនមែនក្រោយបុគ្គលិករត់សំបុត្រផ្ទៃក្នុងឡើយ។ ជារួម មក នីតិវិធីនៃការជូនដំណឹង ដែលត្រូវបានយកមកអនុវត្តលើដីកាសម្រេចលេខ D5/2/3 មិនអនុញ្ញាតឱ្យបញ្ជាក់ផ្ទៀងផ្ទាត់ថា លោក Robert Hamill ឬ សហមេធាវីរបស់ខ្លួន ពិតជាបានទទួលបានដីកាសម្រេចនេះឡើយ។

[៣២] ឧទាហរណ៍ មូលដ្ឋានទី ១ និងទី ២ នៃបណ្ដឹងឧទ្ធរណ៍ តវ៉ាលើការបដិសេធពាក្យសុំនេះ ដោយផ្អែកលើមូលដ្ឋានថា ម្ចាស់ បណ្ដឹងឧទ្ធរណ៍ គឺជា "ជនរងគ្រោះដោយប្រយោល" ដែលតាមពិត សំអាងហេតុចំពោះការបដិសេធ ត្រូវបានដាក់បញ្ចូលនៅក្នុង ដីកាសម្រេចក្នុងសំណុំរឿង ០០៣ មិនមែននៅក្នុងដីកាដែលបានចេញនៅក្នុងសំណុំរឿង ០០៤ ឡើយ។ ជាក់ស្ដែង នេះជាផល វិបាកសម្រាប់មេធាវី ដែលមិនមានលទ្ធភាពពិនិត្យមើលដីកាដែលត្រូវបានជំទាស់ពិតប្រាកដនៅក្នុងសំណុំរឿង ០០៤។ ដូច្នេះ ទើបមេធាវីបានប្រើប្រាស់ទឡ្ហីករណ៍ដែលពាក់ព័ន្ធនឹងដីកាសម្រេចនៅក្នុងសំណុំរឿង ០០៣ ឡើងវិញ។

កាលមុនអង្គសេចក្តី ចំពោះដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត[៣៣] និងនៅក្នុងការជំរុញឱ្យចាប់ផ្តើមគិតគូរអំពីរយៈពេលកំណត់ក្នុងការដាក់ឯកសារ[៣៤] ដែលអនុវត្តចំពោះបណ្តឹងឧទ្ធរណ៍ក្នុងដំណាក់កាលមុនអង្គសេចក្តី និងផលប៉ះពាល់លើសុពលភាពនៃបណ្តឹងឧទ្ធរណ៍នោះ[៣៥]។

១២. យើងយល់ឃើញថា ការដែលពុំមានការជូនដំណឹងអំពីដីកាសម្រេចក្នុងសំណុំរឿង 00៤ ដល់មេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ និងការដែលពុំមានភស្តុតាងច្បាស់លាស់អំពីការជូនដំណឹងដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ គឺជាកំហុសនីតិវិធី ដែលរំលោភបំពានលើសិទ្ធិសារវ័ន្តរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍។ អាស្រ័យហេតុនេះ នៅពេលពិនិត្យឃើញថា បណ្តឹងឧទ្ធរណ៍នេះបានប្តឹងប្រឆាំងនឹងដីកាសម្រេចក្នុងសំណុំរឿង 00៣ ពោលគឺមិនមែនប្តឹងប្រឆាំងនឹងដីកាសម្រេចក្នុងសំណុំរឿង 00៤ ដែលមានសំអាងហេតុនៃការបដិសេធលើពាក្យសុំខុសពីសំអាងហេតុ ដែលបានរៀបរាប់នៅក្នុងដីកាសម្រេចក្នុងសំណុំរឿង 00៣ វានឹងផ្ទុយនឹងផលប្រយោជន៍នៃយុត្តិធម៌ ហើយវានឹងពុំមានភាពយុត្តិធម៌ជាមូលដ្ឋានចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍ នៅក្នុងការយកបណ្តឹងឧទ្ធរណ៍នេះមកពិចារណា។ ទោះបីជាយ៉ាងនេះក្តី យើងកត់សម្គាល់ឃើញថា សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចនេះ ចាប់ផ្តើមកើតមានចាប់តាំងពីពេលជូនដំណឹងអំពីដីកាសម្រេចក្នុងសំណុំរឿង 00៤ ដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ និងមេធាវីតំណាងរបស់គេ ហើយរយៈពេលកំណត់ក្នុងការដាក់បណ្តឹងឧទ្ធរណ៍នឹងចាប់ផ្តើមរាប់ ចាប់ពីពេលនោះដូចគ្នា។ យើងដាក់ភ្ជាប់មតិយោបល់របស់យើង (ឧបសម្ព័ន្ធ ក) អមមកជាមួយនឹងដីកាសម្រេចនៅក្នុងសំណុំរឿង 00៤ នេះ ដើម្បីធ្វើយ៉ាងណាឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ និងមេធាវីរបស់គេទទួលបានការជូនដំណឹងបានត្រឹមត្រូវ។ យើងក៏បានដាក់អមជាមួយនូវឯកសារទាំងឡាយដូចតទៅនេះ ដែលមានសារៈសំខាន់សម្រាប់ការយល់ដឹងនូវសេចក្តីសន្និដ្ឋានរបស់យើងថា ដីកាសម្រេចនេះមិនបានជូនដំណឹងឱ្យបានត្រឹមត្រូវជូនម្ចាស់បណ្តឹងឧទ្ធរណ៍ និងសហមេធាវីរបស់គេ ពីព្រោះពួកគេទាំងអស់គ្នាមិនមានលទ្ធភាពពិនិត្យសំណុំរឿងឡើយ៖ ខ) ឯកសារដែលបានដាក់ និងសេចក្តីណែនាំនៃការជូនដំណឹងអំពីដីកាសម្រេចក្នុងសំណុំរឿង 00៤ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២0១១ ដែលត្រូវបានបញ្ជូនដោយមន្ត្រីគ្រប់គ្រងសំណុំរឿងជូនទៅអង្គបុរេជំនុំជម្រះ គ) ការទទួលស្គាល់នៃការជូនដំណឹង ដែលបានចុះហត្ថលេខាដោយ

---

[៣៣] វិធាន ៧៤(៤)(ខ) និងវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង។

[៣៤] វិធាន ៧៥ និងវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង។

[៣៥] វិធាន ៣៩(១) នៃវិធានផ្ទៃក្នុង។

[redacted] មកពីផ្នែក សេវាកម្មទូទៅ ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១១ គ) វិក្កយបត្របញ្ជាទិញរបស់ក្រុមហ៊ុន TNT លេខ GD 9960664631WW និង ឃ) កំណត់ហេតុនៃការបញ្ជូនដីការបស់ក្រុមហ៊ុន TNT លេខ GD99606431WW។ យើងកត់សម្គាល់បន្ថែមទៀតថា ដោយពិនិត្យឃើញនូវអនិយ័តភាពនៃនីតិវិធី ដែលបានកើតឡើងនៅក្នុងរឿងក្តីនេះ សេចក្តីពិចារណាឡើងវិញលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ គួរត្រូវបានសហចៅក្រមស៊ើបអង្កេតយកមកពិចារណាឱ្យបានហ្មត់ចត់ បន្ទាប់ពីបានគោរពទៅតាមនីតិវិធីដ៏ត្រឹមត្រូវ ដោយរួមបញ្ចូលទាំងការអនុញ្ញាតម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលបាននូវឱកាសដើម្បីកែប្រែពាក្យសុំរបស់គាត់ ឬបោះបង់ចោលការដាក់ពាក្យសុំ នៅក្នុងករណីដែលគាត់សម្រេចថា គាត់ពុំមានមូលហេតុជឿជាក់ថា ព្យសនកម្មដែលគាត់បានអះអាង ពិតជាមានទំនាក់ទំនងចាំបាច់ជាមួយនឹងឧក្រិដ្ឋកម្មនានាដែលមាននៅក្នុងសំណុំរឿង ០០៤ និងមានឱកាសអាចទទួលបានព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត ដែលសហចៅក្រមស៊ើបអង្កេតអាចផ្តល់ឱ្យបាន[៣៦]។

១៣. ដោយពិចារណាឃើញនូវកាលៈទេសៈទាំងនេះ យើងយល់ឃើញថា យើងមិនអាចពិភាក្សាលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នេះបានឡើយ។ ទោះបីជាយ៉ាងនេះក្តី យើងសូមបង្ហាញនូវសេចក្តីអង្កេតរបស់យើងជាថ្មីម្តងទៀត នៅក្នុងសំណុំរឿងនេះ ដូចដែលយើងបានធ្វើឡើងនៅក្នុងសំណុំរឿង ០០៣[៣៧]។ ចំណុចទីមួយ បញ្ហាទាំងអស់ ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ត្រូវយកមកពិនិត្យជាមុន មុនពេលចៅក្រមឈានដល់សេចក្តីសន្និដ្ឋានណាមួយថា សិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍មិនត្រូវបានរំលោភបំពាន ដោយសារការបដិសេធ មិនទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះឡើយ។ ចំណុចទីពីរ អង្គហេតុថ្មីត្រូវបានដាក់បញ្ចូលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី[៣៨] ហើយ ទោះបីក្នុងករណីណាក៏ដោយ វានេះពុំមានអានុភាពប៉ះពាល់លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ អនុលោមតាមវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង។ ចំណុចទីបី ការពិភាក្សាថាតើនៅក្នុងពេលនេះ មាន ឬពុំមាន "ជនត្រូវ

---

[៣៦] ក្នុងរយៈពេលដ៏ខ្លី បន្ទាប់ពីចូលកាន់តំណែងរបស់គាត់ យើងឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានជូនដំណឹងជាសាធារណៈថា គាត់នឹងប្រឹងប្រែងជូនដំណឹងដល់សាធារណៈជនអំពីការវិវត្តន៍នៅក្នុងសំណុំរឿង ០០៣ និង ០០៤ (សេចក្តីប្រកាសពត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១១)។

[៣៧] មតិយោបល់នៅក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ១៦។

[៣៨] ករណីខ្វែងយោបល់គ្នាលេខ ០០១/១៨-១១-២០០៨-អ.វ.ត.ក/អបជ សេចក្តីពិចារណានៃអង្គបុរេជំនុំជម្រះទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ មតិយោបល់របស់ចៅក្រម Lahuis និង Downing។

ចោទ” នៅក្នុងសំណុំរឿង ០០៤ នេះ គឺវាពុំមានភាពចាំបាច់ក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះឡើយ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចសម្រេចលើអង្គសេចក្តីនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចសហចៅក្រមស៊ើបអង្កេតបានធ្វើឡើង។ ឧបសគ្គណាមួយដែលរារាំងចំពោះការធ្វើសេចក្តីសម្រេច ដូចបានចោទប្រកាន់នៅពេលនេះ គួរតែនាំឱ្យយើងសន្និដ្ឋានថា សេចក្តីសម្រេចលើភាពអាចទទួលយកបាននេះ ត្រូវព្យួរទុកសិន រហូតទាល់តែមានព័ត៌មានគ្រប់ទាំងអស់។ ៕

**នៅភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២**

**Rowan DOWNING** **Katinka LAHUIS**